ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៨៧៩ មស.សង៣

## សេចក្ដីជូនដំណឹង
## ស្ដីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្ដល់ប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែ មេសា-ឧសភា ឆ្នាំ ២០១៧

យោងសារាចរលេខ ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្ដីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្ដល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល ។

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមគោរពជម្រាបជូន សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត មេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃសារាចរ ដូចមានយោងខាងលើ ឱ្យមានប្រសិទ្ធភាព ក្រសួងមុខងារសាធារណៈ សូមដាក់ចេញនូវសេចក្ដីជូនដំណឹងសម្រាប់សហការអនុវត្តដូចខាងក្រោម៖

- សម្រាប់ការបើកផ្ដល់បៀវត្សប្រចាំខែមេសា ឆ្នាំ២០១៧ ជូនមន្ត្រីរាជការស៊ីវិលឱ្យបានមុនថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១៧ ក្រសួងមុខងារសាធារណៈ សូមស្នើសុំគ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ រាជធានី ខេត្ត ពុំចាំបាច់សុំធ្វើការបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ សម្រាប់ខែមេសា ឆ្នាំ២០១៧ទេ លើកលែងករណីផ្ទេរក្របខ័ណ្ឌដែលត្រូវផ្អាក់បៀវត្សក្នុងខែមេសា ។
- ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សខែមេសា ឆ្នាំ២០១៧ ដោយផ្អែកលើទិន្នន័យដែលមានក្នុងតារាងទូទាត់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែមីនា ឆ្នាំ២០១៧ជាគោល និងធ្វើការរៀបចំទិន្នន័យមួយចំនួនទៀតជាស្វ័យប្រវត្តិទៅតាមគោលការណ៍ថ្មីរបស់រាជរដ្ឋាភិបាល ។
- ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវធានាការបើកផ្ដល់ប្រាក់បៀវត្សប្រចាំខែមេសា ឆ្នាំ២០១៧ ជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួន ឱ្យបានយ៉ាងយូរក្នុងសប្ដាហ៍ទី២ នៃខែមេសា ឆ្នាំ២០១៧ ។
- សម្រាប់ការបើកផ្ដល់បៀវត្សប្រចាំខែឧសភា ឆ្នាំ២០១៧ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវស្នើសុំប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ មកក្រសួងមុខងារសាធារណៈ ត្រឹមសប្ដាហ៍ទី ៣ នៃខែ មេសា ឆ្នាំ២០១៧ ដើម្បីធានាការបើកផ្ដល់ប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួនឱ្យបានយ៉ាងយូរក្នុងសប្ដាហ៍ទី ៣ នៃខែឧសភា ឆ្នាំ២០១៧ ។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះ តាមការគួរ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ